ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 02-Dec-2014, 09:43
CMS/CFO: Sann Rada

**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តី នួន ជា

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ២០១៤

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ អង្គជំនុំជម្រះ : **សាធារណៈ/Public**

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើបន្ទាន់ សុំការពិចារណាឡើងវិញលើចំនួនទំព័រកំណត់លើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងករណី០០២/០១**

---

**ដាក់ដោយ:**

**ក្រុមមេធាវីការពារក្តី នួន ជា:**

សុន អរុណ

Victor KOPPE

ព្រុំ ផល្លា

សួន វិសាល

លីវ សុវណ្ណា

Doreen CHEN

Joshua ROSENSWEIG

Xiaoyang NIE

**ចម្លងជូន:**

**សហចៅក្រមជាប់ចោទ**

**សហព្រះរាជអាជ្ញា:**

ជា លាង

Nicholas KOUMJIAN

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Marie GUIRAUD

អនុលោមតាមវិធាន ៣៩ (៤) នៃវិធានផ្ទៃក្នុងរបស់ អវតក សហមេធាវីការពារក្ដី នួន ជា (“មេធាវីការពារក្ដី”) តទៅនេះសូមដាក់សំណើបន្ទាន់ សុំការពិចារណាឡើងវិញលើចំនួនទំព័រកំណត់លើបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងករណី០០២/០១:

១. នៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសសាលក្រមលើសំណុំរឿង ០០២/០១ (“សាលក្រម”)[1]។ នៅថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៤ ក្រុមមេធាវីការពារក្ដីរបស់ ខៀវ សំផន និង នួន ជា បានរួមគ្នាដាក់សំណើសុំពន្យារពេល និង ចំនួនទំព័របន្ថែមសម្រាប់សេចក្ដីជូនដំណឹងនៃបណ្ដឹងសាទុក្ខ និងសារណាបណ្ដឹងសាទុក្ខ[2]។ នៅថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០១៤ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាថាចំនួនទំព័រកំណត់នៃបណ្ដឹងសាទុក្ខនឹងកំណត់នៅពេលណាដែលសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខត្រូវបានដាក់រួចហើយ[3]។ នៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ មេធាវីការពារក្ដីបានដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រម (“សេចក្ដីជូនដំណឹង”)[4]។ នៅថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ មេធាវីការពារក្ដីបានដាក់សំណើជាថ្មីម្ដងទៀត សុំចំនួនទំព័របន្ថែមដោយមិនមានការកំណត់ចំនួនទំព័រ ឬជាជម្រើសម៉្យាងទៀត សូមចំនួន ៥០០ទំព័រ[5]។ អង្គជំនុំជម្រះបានអនុញ្ញាតរហូតដល់ ២១០ទំព័រ។[6]

២. ដោយសារតែតុលាការកំពូលបានចេញសេចក្ដីសម្រេចនៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ មេធាវីការពារក្ដីសុំការធានាក្នុងការកំណត់ទៅលើចំនួនទំព័រកំណត់នៃសារណារបស់ខ្លួនឲ្យបានកាន់តែវែង កាន់

---

[1] ឯកសារ E313 “សាលក្រមសំណុំរឿង ០០២/០១” ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤។

[2] ឯកសារ F3 , “សំណើបន្ទាន់របស់មេធាវីការពារក្ដីលោក ខៀវ សំផន និង មេធាវីការពារក្ដីលោក នួន ជា សុំពន្យារពេលកំណត់ និងបង្កើនចំនួនទំព័រនៃបណ្ដឹងសាទុក្ខ” ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៤។

[3] ឯកសារ F3/3 “សេចក្ដីសម្រេចលើសំណើរបស់មេធាវីការពារក្ដីសុំពន្យារពេល និងបន្ថែមចំនួនទំព័រលើសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ និងសារណានៃបណ្ដឹងសាទុក្ខ” ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៤។

[4] ឯកសារ E313/1/1 “សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១” ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ (“សេចក្ដីជូនដំណឹង”)

[5] ឯកសារ F6 “សំណើលើកទីពីរសុំពន្យារពេល និងបន្ថែមចំនួនទំព័រសម្រាប់បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១” ថ្ងៃទី០២ ខែ តុលា ឆ្នាំ ២០១៤។

[6] ឯកសារ F9 “សេចក្ដីសម្រេចលើសំណើសុំពន្យាររយៈពេល និងបន្ថែមចំនួនទំព័រសម្រាប់សារណាបណ្ដឹងសាទុក្ខ និងសារណាតប” ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០១៤។

តែល្អ។ ហើយខ្លួនបានសម្រេចចិត្តដកចេញនូវមូលដ្ឋានខ្លះនៃបណ្ដឹងសាទុក្ខ បើទោះជាមូលដ្ឋាននោះនៅតែសំខាន់សម្រាប់សំណុំរឿងលោក នួន ជា យ៉ាងណាក្ដី។ ដោយសារតែមិនមានការបន្ថែមចំនួនទំព័រ មេធាវីការពារក្ដីត្រូវបានបង្ខំឲ្យជ្រើសរើសរវាងការបោះបង់ចោលមូលដ្ឋានបន្ថែម និងការលុបចោលនូវអំណះអំណាងសំខាន់ៗក្នុងការគាំទ្របណ្ដឹងសាទុក្ខ ដែលខ្លួនរក្សាទុក។ ដូចដែលសហព្រះរាជអាជ្ញាបានលើកឡើងយ៉ាងត្រឹមត្រូវនៅក្នុងសំណើសុំចំនួនទំព័របន្ថែមសម្រាប់បណ្ដឹងសាទុក្ខរបស់ខ្លួននៅក្នុងសំណុំរឿង០០១ ថា :

> ឥឡូវនេះសហព្រះរាជអាជ្ញាបានបំពេញរួចរាល់ហើយនូវសារណាលើបណ្ដឹងសាទុក្ខដោយពិនិត្យមើលម៉ត់ចត់លើការរកឃើញនានាផ្នែកអង្គហេតុ និងអង្គច្បាប់ដែលនៅក្នុងសាលក្រមដើម្បីគាំទ្រដល់បណ្ដឹងសាទុក្ខរបស់ខ្លួន។ ក៏ប៉ុន្តែ ពង្រាងចុងក្រោយជាភាសាអង់គ្លេស រួមទាំងទំព័រមុខ មាតិការឿង និងសេចក្ដីសន្និដ្ឋានទាក់ទងនឹងនីតិវិធី និងសេចក្ដីសន្និដ្ឋានដ៏មានសារៈសំខាន់ផង បានឡើងរហូតទៅដល់ ៦៥ទំព័រ។ បន្ទាប់ពីការវាយតម្លៃជាលម្អិតមួយទៅលើសេចក្ដីសន្និដ្ឋានលើបណ្ដឹងសាទុក្ខ សហព្រះរាជអាជ្ញាបានធ្វើសេចក្ដីសន្និដ្ឋានថា ការកាត់បន្ថយណាមួយចេញពីចំនួនទំព័រខាងលើនេះ គឺមុខជានឹងធ្វើឲ្យខូចដល់បូរណភាពនៃសេចក្ដីសំអាងរបស់ខ្លួន ហើយនឹងមិនបំរើឲ្យផលប្រយោជន៍យុត្តិធម៌នោះឡើយ[7]។

ក្នុងការឆ្លើយតបទៅនឹងសំណើសមហេតុផលនេះ អង្គជំនុំជម្រះបានអនុញ្ញាតបន្ថែមចំនួនទំព័រ[8]។

៣. មេធាវីការពារក្ដីកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាបានដាក់សារណាបណ្ដឹងសាទុក្ខរបស់ខ្លួនមានកម្រាស់ ៣០ទំព័រ សម្រាប់ការពន្យល់លើមូលដ្ឋានតែមួយលើបណ្ដឹងសាទុក្ខដែលមូលដ្ឋាននេះត្រូវបានប្ដឹងចំនួនពីរដងរួចមកហើយនៅក្នុងតុលាការនេះ[9]។ ផ្ទុយទៅវិញបណ្ដឹងសាទុក្ខនេះបានលើកឡើងអំពីបញ្ហាច្បាប់ និងនីតិវិធីជាងដប់ ដែលមិនត្រូវបានដោះស្រាយដោយអង្គជំនុំជម្រះណាមួយ លើកលែងតែអង្គជំនុំជម្រះសាលាដំបូង (ឬក៏ សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងផ្ទុយពីការ

---

[7] សំណុំរឿង ០០១/១៨-០៧-២០០៧- អវតក/អជតក ឯកសារលេខ F5/1 "សំណើរបស់សហព្រះរាជអាជ្ញា សុំបន្ថែមចំនួនទំព័រដើម្បីដាក់សេចក្ដីសន្និដ្ឋានបណ្ដឹងសាទុក្ខរបស់ខ្លួន" ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ២។

[8] សំណុំរឿង ០០១/១៨-០៧-២០០៧- អវតក/អជតក ឯកសារលេខ F5/2 "សេចក្ដីសម្រេចលើសំណើពីររបស់សហព្រះរាជអាជ្ញា សុំបន្ថែមចំនួនទំព័រសម្រាប់ការដាក់សារណាបណ្ដឹងសាទុក្ខរបស់ខ្លួន" ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០។

[9] ឯកសារ F11 "បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿងលេខ ០០២/០១" ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤។

សម្រេចកាលពីលើកមុន មានដូចជា និយមន័យនៃការសម្លាប់រង្គាល និងការធ្វើទុកបុកម្នេញ និង ទំនាក់ទំនង (nexus) នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅពេលមានជម្លោះប្រដាប់អាវុធ)។ មេធាវីការពារក្ដីត្រូវបានបង្ខំឲ្យលើកឡើងអំពីអំណះអំណាងនេះ ដែលចិតក្នុងភាពស្មុគស្មាញដូចគ្នាទៅនឹងបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា តែបែរជាអាចធ្វើបានតែពីរឬបីទំព័រទៅវិញ។

៤. ក្រុមមេធាវីការពារក្ដីកត់សម្គាល់សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះនេះថា "ការដាក់កម្រិតលើចំនួនទំព័រ មិនមែនដោយសារការពិចារណាលើទស្សនវិជ្ជាផ្នែកច្បាប់ឡើយ តែលើប្រសិទ្ធភាពរបស់តុលាការ"[10]។ ប៉ុន្តែក្រុមមេធាវីការពារក្ដីរំលឹកថា ការដាក់កំហិតនៃប្រសិទ្ធភាពតុលាការមិនអនុវត្តចំពោះសារណាសំខាន់បំផុតនាពេលថ្មីៗនេះរបស់សហព្រះរាជអាជ្ញាឡើយ។ មាត្រា៥.៥ នៃការអនុវត្តស្ដីពីការដាក់ឯកសារ មិនចែងពីការកម្រិតចំនួនទំព័រទាក់ទងនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម និងដីកាសន្និដ្ឋានស្ថាពរ។ អនុលោមតាមការសម្រេចនេះសហព្រះរាជអាជ្ញាដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរកម្រាស់ ១១៤៩ទំព័រ[11] បង្កនូវឥទ្ធិពលយ៉ាងធំលើការដឹកនាំកិច្ចស៊ើបសួររបស់តុលាការ។ ការចូលរួមរបស់ជនជាប់ចោទនៅក្នុងដំណើរការនេះគឺសឹងតែសូន្យ។ ទើបតែប៉ុន្មានឆ្នាំក្រោយមកក្រុមមេធាវីការពារក្ដីមានឱកាសដ៏កម្រិតលើកឡើងអំពីសំណុំរឿងរបស់ខ្លួននៅក្នុងសេចក្ដីសន្និដ្ឋានស្ថាពរបញ្ចប់សវនាការលើភស្ដុតាង។ សារណាបណ្ដឹងសាទុក្ខនៅក្នុងសំណើនេះ ជាឱកាសទីពីរ និងចុងក្រោយ។ ដូច្នេះការអនុវត្តរបស់ប្រព័ន្ធច្បាប់ស៊ីវិលនៃការមិនកម្រិតចំនួនទំព័រលើសារណា(មួយចំនួន) ត្រូវបានចូលរួមជាមួយការអនុវត្តរបស់ប្រព័ន្ធច្បាប់ common law នៃការដាក់កម្រិតចំនួនទំព័រនៃសារណា(ដ៏ទៃទៀត) ដែលប៉ះពាល់ដល់ជនជាប់ចោទ។ ការអនុវត្តនីតិវិធី cherry-picking ពីប្រព័ន្ធច្បាប់ដែលមានលក្ខណៈប្រកួតប្រជែងគ្នា បង្កឲ្យមានបញ្ហា

---

[10] ឯកសារ **F9** "សេចក្ដីសម្រេចលើញត្តិសុំពន្យាពេលវេលា និងបន្ថែមចំនួនទំព័រសម្រាប់សារណាបណ្ដឹងសារទុក្ខ និងចម្លើយតប" ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ នៅកថាខណ្ឌ១៥។

[11] ឯកសារ **D3** "ដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរ ឯកសារលេខ០០៨" ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៧, ឯកសារ **D83**, "ដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងមន្ទីរសន្តិសុខភូមិភាគឧត្តរ" ចុះថ្ងៃទី២៦ ខែមិនា ឆ្នាំ ២០០៨។ ឯកសារ **D196** ដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទៅលើជនជាតិចាម" ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៩ ។ ឯកសារ **D390** សេក្ដីសន្និដ្ឋានស្ថាពរអនុលោមតាមវិធាន៦៦ របស់សហព្រះរាជអាជ្ញា" ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០។

នៅទូទាំងការស៊ើបសួរ និងការជំនុំជម្រះក្នុងករណី០០២/០១ និង បង្កើតបានជាទឡ្ហីករណ៍ជាច្រើនសម្រាប់ការប្តឹងសាទុក្ខនៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ។

៥. នៅពេលនេះក្រុមមេធាវីការពារក្តីពង្រាងភាគច្រើននៃសារណាបណ្តឹងសាទុក្ខរបស់ខ្លួន ហើយអាចវាយតម្លៃច្បាស់លាស់លើវិសាលភាពដែលតម្រូវសម្រាប់សារណាបណ្តឹងសាទុក្ខប្រកបដោយប្រសិទ្ធភាពប្រឆាំងនឹងសាលក្រម។ នៅពេលនេះសារណាបណ្តឹងសាទុក្ខមានកម្រាស់២៣២ទំព័រ។ ទឡ្ហីករណ៍សំខាន់ៗ កំពុងតែពង្រាងនៅឡើយ ហើយក្រុមមេធាវីការពារក្តីរំពឹងថា ចំនួនទំព័រចុងក្រោយនឹងឈានដល់២៨០ទំព័រ។ ក្រុមមេធាវីការពារក្តីកំពុងតែខិតខំ ហើយនិងបន្តការខិតខំយ៉ាងពេញទំហឹង ដើម្បីសម្រិតសម្រាំងនូវអំណះអំណាងឲ្យកាន់តែសាមញ្ញ និងកាត់បន្ថយចំនួនទំព័រសម្រាប់សារណានៃបណ្តឹងសាទុក្ខនេះ។ តែប្រសិនបើមិនអាចធ្វើទៅបាន ក្រុមមេធាវីការពារក្តីស្នើសុំអង្គជំនុំជម្រះតុលាការកំពូលបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងសាទុក្ខរបស់ខ្លួនចំនួន៦០ទំព័រទៀតដែលសរុបទាំងអស់មានចំនួន២៧០ទំព័រ។ ដោយសារភាពលំអៀងយ៉ាងខ្លាំងចំពោះឱកាសរបស់ភាគីដើម្បីបញ្ចេញទ្រឹស្តីករណីរបស់ខ្លួនក្នុងសំណុំរឿង០០២[12] ការបដិសេធអំណះអំណាងចំនួន៦០ទំព័រនៅពេលបិទដំណើរការនឹងរំលោភសិទ្ធិរបស់ នួន ជា ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងជាពិសេសសមភាពនៃមធ្យោបាយនៃការតទល់ក្តី។

៦. ដោយសារពេលវេលាកំណត់នៃការដាក់សារណាបណ្តឹងសាទុក្ខជិតមកដល់ ក្រុមមេធាវីការពារក្តីស្នើជាបន្ទាន់នូវសេចក្តីសម្រេចឲ្យបានឆាប់បំផុត តាមតែអាចធ្វើបាន ដោយមូលហេតុនឹងចេញនៅពេលក្រោយ ប្រសិនបើចាំបាច់។ សម្រាប់ហេតុផលដូចគ្នានេះ និងដោយពិចារណាដល់ភាពងាយស្រួលរបស់សំណើនេះ មេធាវីការពារក្តីសូមទទូចឲ្យសហព្រះរាជអាជ្ញាឆ្លើយតបនឹងសំណើនេះ ឬក៏បង្ហាញពីចេតនារបស់ខ្លួនក្នុងការមិនឆ្លើយតបឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

**សហមេធាវីការពារក្តី នួន ជា**

សុន អារុណ Victor KOPPE

[12] សូមមើលកថាខណ្ឌ៤ខាងលើ។